N: 7
23-2-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៧ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I – ខុទ្ទកាល័យព្រះមហាក្សត្រ

១- ព្រះរាជក្រម

១៨- ០២- ៩៧	ព្រះរាជក្រម នស.រកម/០២៩៧/០២ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីតំបន់អាស៊ីអគ្នេយ៍ គ្មានអាវុធនុយក្លេអ៊ែរ	៤៤៣

២- ព្រះរាជក្រឹត្យ

១៩- ០២- ៩៧	ព្រះរាជក្រឹត្យ នស/រកត/០២៩៧/១០ តែងតាំងលោក **ខូច ជូលី** ជាឧកញ៉ា	៤៤៥
២១- ០២- ៩៧	ព្រះរាជក្រឹត្យ នស/រកត/០២៩៧/១១ តែងតាំងឯកឧត្តម **ខួន ផនស៊ីផុន** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានចំការកៅស៊ូ	៤៤៦

II – ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

១៧- ០២- ៩៧	អនុក្រឹត្យលេខ ១១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រី រាជការ	៤៤៧
១៩- ០២- ៩៧	អនុក្រឹត្យលេខ ១២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រី រាជការ	៤៤៨
២១- ០២- ៩៧	អនុក្រឹត្យលេខ ១៣ អនក្រ. ស្តីពីការអោយចូលនិវត្តន៍មន្ត្រីរាជការ	៤៤៩

២ - សេចក្តីសំរេច

១៦- ០២- ៩៧	សេចក្តីសំរេចលេខ ០៨ សសរ.	៤៥០

III – ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

១៧- ០២- ៩៧	ប្រកាសលេខ ០២៦ សហវ. ប្រក. ពជ ស្ដីពីការតែងតាំងសមាសភាពគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់	៤៥២
១៨- ០២- ៩៨	ប្រកាសលេខ ០២៧ សហវ. ប្រក. លសា ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃនាយកដ្ឋានលទ្ធកម្មសាធារណៈ	៤៥៤

២ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

១៧- ០២- ៩៧	ប្រកាសលេខ ១៤២ ភរ. ប្រក. អនុញ្ញាតអោយក្រុមហ៊ុន Khaou chuly Dévelopment Co,.Ltd និងក្រុមហ៊ុន Tong YANG Cement Corporation ធ្វើអាជីវកម្មផលិតស៊ីម៉ង់ត៍នៅតំបន់ទូកមាស	៤៦២
១៧- ០២- ៩៧	ប្រកាសលេខ ១៥៣ ផក. ប្រក. អនុញ្ញាតអោយលោក **ផាន់ គីមហៀង** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតឥដ្ឋក្បឿង	៤៦៣
១៧- ០២- ៩៧	ប្រកាសលេខ ១៥៤ ផក. ប្រក. អនុញ្ញាតអោយលោក **ម៉ា ឆួក** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតនំប៉័ង	៤៦៤
១៧–០២–៩៧	ប្រកាសលេខ ១៥៥ ផក. ប្រក. អនុញ្ញាតអោយលោក **លឹម ថាន់** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការរោងជាងផ្សារ និង ជួសជុលបន្ទាស់រថយន្ត	៤៦៥

គ

១៧- ០២- ៩៧	ប្រកាសលេខ ១៥៦ ផក.ប្រក. អនុញ្ញាតអោយលោក **ឌី ពិសិទ្ធ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាម្ចាស់ឧស្សាហកម្ម តូចម្ហូបចាំ ផ្ទេរភារកិច្ចគ្រប់គ្រងជូនលោក **ម៉ឺឆៃ ឡាំតចនុតេទ្ធ**	៤៦៥
១៨- ០២- ៩៧	ប្រកាសលេខ ១៧៤ ផក.ប្រក.អនុញ្ញាតអោយក្រុមហ៊ុន អ៊ិនធីណេសូណាល់ ស្មៀល អ៊ិនដាស់ស្ទ្រីល តំណាងអោយ លោក **តាំងម៉េងហ៊ុយ** ជនជាតិខ្មែរ បង្កើតរោងចក្រកែច្នៃ សង្កសី	៤៦៦
១៨- ០២- ៩៧	ប្រកាសលេខ ១៨៩ ផក.ប្រក.អនុញ្ញាតអោយលោក **ចាម ចិន្តា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាង ផលិតទ្វារបង្អួចដែក	៤៦៧
១៨- ០២- ៩៧	ប្រកាសលេខ ១៩០ ផក.ប្រក.អនុញ្ញាតអោយលោក **ឆៃ ហោខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោង ជាងផ្សារទ្វារដែក	៤៦៨
១៨- ០២- ៩៧	ប្រកាសលេខ ១៩១ ផក.ប្រក. អនុញ្ញាតអោយលោក **ហោ ឌន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាង ផ្សារដែក	៤៦៨
១៨- ០២- ៩៧	ប្រកាសលេខ ១៩២ ផក.ប្រក. អនុញ្ញាតអោយអ្នកស្រី **ថាំ ស៊ីន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាង ផ្សារដែក	៤៦៩
១៨- ០២- ៩៧	ប្រកាសលេខ ១៩៣ ផក.ប្រក. អនុញ្ញាតអោយលោក **ស សារ៉ាត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោង ជាងផ្សារដែក	៤៧០

ឃ

១៨- ០២- ៩៧	ប្រកាសលេខ ១៩៤ ផក.ប្រក.អនុញ្ញាតអោយលោក **លឹម ហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងក្រឡឹងដែក	៤៧០
១៨- ០២- ៩៧	ប្រកាសលេខ ១៩៥ផក.ប្រក.អនុញ្ញាតអោយលោក **ឈៀង ម៉ុង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនក្រឡឹងដែក ។	៤៧១
១៨- ០២- ៩៧	ប្រកាសលេខ ១៩៦ផក.ប្រក.អនុញ្ញាតអោយលោក**ឈៀង កាន់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងក្រឡឹងដែក	៤៧១
១៨- ០២- ៩៧	ប្រកាសលេខ ១៩៧ ផក.ប្រក.អនុញ្ញាតអោយលោក **ឃាង ម៉ុង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងក្រឡឹងដែក	៤៧២
១៨- ០២- ៩៧	ប្រកាសលេខ ១៩៨ផក.ប្រក. អនុញ្ញាតអោយលោក **ឃិន គិតឡេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតទឹកកកដើម ។	៤៧២
១៨- ០២- ៩៧	ប្រកាសលេខ ១៩៩ផក.ប្រក.អនុញ្ញាតអោយលោក **សៀត សុខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតឥដ្ឋក្បឿង	៤៧៣
១៨- ០២- ៩៧	ប្រកាសលេខ ២០០ ផក.ប្រក អនុញ្ញាតអោយលោក **ហុក ឈួង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ- ក្បឿង	៤៧៣
១៨- ០២- ៩៧	ប្រកាសលេខ ២០១ផក.ប្រក. អនុញ្ញាតអោយលោក**ម៉េង ហ៊ុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋក្បឿង	៤៧៤
១៨- ០២- ៩៧	ប្រកាសលេខ ២០២ផក.ប្រក. អនុញ្ញាតអោយលោក **លឹម គង់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតឥដ្ឋក្បឿង	៤៧៤

១៨- ០២- ៩៧	ប្រកាសលេខ ២០៣ផក.ប្រក. អនុញ្ញាតជូនលោក **សួន ហេង** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋក្បឿង	៤៧៥
១៨- ០២- ៩៧	ប្រកាសលេខ ២០៤ផក.ប្រក.អនុញ្ញាតជូនលោក **ម៉ុន ឆាន់** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ	៤៧៥
១៨- ០២- ៩៧	ប្រកាសលេខ ២០៥ ផក.ប្រក. អនុញ្ញាតជូនលោកស្រី **ឡេង ថាវ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២៩ សេះ	៤៧៦
១៨- ០២- ៩៧	ប្រកាសលេខ ២០៦ ផក.ប្រក. អនុញ្ញាតជូនលោក **យិន ខ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៥០ សេះ	៤៧៦
១៨- ០២- ៩៧	ប្រកាសលេខ ២០៧ ផក.ប្រក.អនុញ្ញាតអោយលោក **គោ យ៉ូ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ	៤៧៧
១៨- ០២- ៩៧	ប្រកាសលេខ ២០៩ ផក.ប្រក. អនុញ្ញាតអោយលោក **យិន ម៉ាន់** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ	៤៧៨
១៨- ០២- ៩៧	ប្រកាសលេខ ២១០ ផក.ប្រក. អនុញ្ញាតអោយលោក **ឈឿន នួយ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៧៧ សេះ	៤៧៨
១៨- ០២- ៩៧	ប្រកាសលេខ ២១១ ផក.ប្រក. អនុញ្ញាតអោយលោក **ម៉ែន ផាត** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៥១ សេះ	៤៧៩

១៨- ០២- ៩៧ ប្រកាសលេខ ២១២ ប្រក. ផក. ស្តីពីការផ្ទេររោងចក្រទឹកដោះគោ អប្សរា និង ឃ្លាំងរោងចក្រទឹកដោះគោអប្សរារបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ៤៨០

៣ - និស្តិការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

១៨- ០២- ៩៧ ប្រកាសលេខ ០៦៦/៩៧ ពម. ប្រក. អនុញ្ញាតអោយបោះពុម្ពផ្សាយកាសែត ចលនាថ្មី ឡើងវិញ ៤៨២

១៩- ០២- ៩៧ ប្រកាសលេខ ០៦៧/៩៧ ពម. ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ៤៨៤

១៩- ០២- ៩៧ ប្រកាសលេខ ០៦៩/៩៧ ពម. ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ៤៨៦

២០- ០២- ៩៧ ប្រកាសលេខ ០៧១/៩៧ ពម. ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ៤៨៧

៤ - និស្តិការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

១៨- ០២- ៩៧ ប្រកាសលេខ ១៥១ អយក. ប្រក. ស្តីពីការបើកសាលាបឋមសិក្សា « ខ្វាវ » ជាឧបសម្ព័ន្ធសាលាបឋមសិក្សា « ទន្លេនាម » ៤៨៩

១៨- ០២- ៩៧ ប្រកាសលេខ ១៥២អយក. ប្រក. ស្តីពីការបើកសាលាបឋមសិក្សា «សាលាសំណាក់» ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា « ដើមស្វាយ » ៤៩១

៥ - និស្តិការ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

ប្រកាស

១៧- ០២- ៩៧ ប្រកាសលេខ ២៦៥ ប្រក. អជប ស្តីពីការបង្កើតក្រុមជំនាញសំរាប់គំរោងអភិវឌ្ឍន៍កសិកម្ម ក្រោមឥណទានធនាគារអភិវឌ្ឍន៍

អាស៊ី លេខ ១៤៤៥ CAM (SF) ៤៩៣

៦- ទីស្ដីការរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

ប្រកាស

១៩- ០២- ៩៧ - ប្រកាសលេខ ១២ ប្រក.បបប/៩៧ ស្ដីពីការបង្កើតក្រុមប្រឹក្សាវិន័យប្រចាំក្រសួងយុត្តិធម៌ ៤៩៦

៧- ក្រសួងកិច្ចការនារី

សេចក្ដីសំរេច

១៨- ០២- ៩៧ សេចក្ដីសំរេចលេខ ១៤៥ កកន. ស្ដីពីការតែងតាំង នាយិកាមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ « សម្ដេចម៉ែ » នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ៤៩៧

១៨- ០២- ៩៧ សេចក្ដីសំរេចលេខ ១៤៦ កកន. ស្ដីពីការតែងតាំង នាយិកាមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ **ឧ.ម៉ារី រណឫទ្ធិ** នៅស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ៤៩៩

១៨- ០២- ៩៧ សេចក្ដីសំរេចលេខ ១៤៧ កកន. ស្ដីពីការតែងតាំង នាយិកាមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ **«សម្ដេច ព្រះមហាក្សត្រិយានី ព្រះកុសុមៈ»** នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ៥០០

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១- ព្រះរាជក្រម

ព្រះរាជក្រម នស/រកត/០២៩៧/០២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-១០៩៤-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស- រកត១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស- រកត- ១០៩៤- ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស- រកម- ០១៩៦- ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

ប្រកាសអោយប្រើ

ច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្ដីពីតំបន់អាស៊ី-អាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧ នាសម័យប្រជុំលើកទី ៧ នីតិកាលទី ១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

ច្បាប់

ស្ដីពី

ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្ដីពីតំបន់អាស៊ី- អាគ្នេយ៍ គ្មានអាវុធនុយក្លេអ៊ែរ

មាត្រា ១.—

អនុម័តយល់ព្រមលើសន្ធិសញ្ញាស្ដីពីតំបន់អាស៊ី-អាគ្នេយ៍ គ្មានអាវុធនុយក្លេអ៊ែរ ដែលចុះហត្ថលេខានៅបាងកក នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.—

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តសន្ធិសញ្ញា នេះ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

បានបង្គំទូលថ្វាយ និង ជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រីទី ១ និង ទី ២
រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

ហត្ថលេខា

អ៊ុង ហួត

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា
ហ៊ុន សែន

* * *

២- ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០២៩៧/១០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ខួច ជូលី

ជា

ខុត្តញ៉ោ

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០២៩៧/១១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស ឧភតោសុជាត

វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញសំណើរបស់នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ឡូន ផនស៊ីថុន ជាអគ្គនាយកនៃអគ្គនាយកដ្ឋានបំការ កៅស៊ូ ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II- រាជរដ្ឋាភិបាល

១- អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ : ១០ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១០៩៤_៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : តែងតាំងលោក **ទី នាយី** ជាទីប្រឹក្សាទទួលបន្ទុកផ្នែកគណនេយ្យ និង ហិរញ្ញវត្ថុ របស់ឯកឧត្តម **សុខ អាន** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី

រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ព្រមទាំងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ១២ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមតំរូវការចាំបាច់របស់រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

សំរេច

មាត្រា ១ : តែងតាំងលោក **ឆោ ឌួ** ជំនួយការឯកឧត្តម **ឃ្វាក់ សុខ** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ មានឋានៈស្មើនឹងប្រធាននាយកដ្ឋាន ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ : ១៣ អនក្រ
ស្តីពីការអោយចូលនិវត្តន៍មន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

សំរេច

មាត្រា ១ : ត្រូវបានអោយចូលនិវត្តន៍លោក **គេង ឡៅ** បច្ចុប្បន្នជាអគ្គនាយកនៃអគ្គនាយកដ្ឋានចំការកៅស៊ូ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ព្រមទាំងលោក **គេង ឡៅ** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ | **ហ៊ុន សែន**

* * *

២- សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ : ០៨ សសរ

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

– យោងតាមសភាពការណ៍មិនប្រក្រតីនៅខេត្តបាត់ដំបង

សម្រេច

ប្រការ ១ : បង្កើតគណៈកម្មការចំរុះមួយ ដែលមានសមាសភាពដូចខាងក្រោម ÷

១–ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ

២–ឯកឧត្តម **យូ ហុកគ្រី** សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

៣–ឯកឧត្តមឧត្តមសេនីយ៍ឯក **ទៀ បាញ់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

៤–ឯកឧត្តមឧត្តមសេនីយ៍ឯក **ទា ចំរ៉ាត់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

៥–ឯកឧត្តមឧត្តមសេនីយ៍ឯក **កែ គឹមយ៉ាន** នាយអគ្គសេនាធិការកងយោធពល ខេមរភូមិន្ទ

៦–ឯកឧត្តមឧត្តមសេនីយ៍ឯក **ហុក ឡងឌី** អគ្គនាយកនគរបាលជាតិ

៧–ឯកឧត្តមឧត្តមសេនីយ៍ឯក **ញឹក ប៊ុនឆៃ** នាយរងទី ១ អគ្គសេនាធិការ កងយោធពលខេមរភូមិន្ទ

៨–ឯកឧត្តមឧត្តមសេនីយ៍ឯក **យ៉េន ម៉ារឌី** អគ្គនាយករងទី ១នគរបាលជាតិ

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចចុះត្រួតពិនិត្យស្រាវជ្រាវ និង ដោះស្រាយ បាតុភាពដែលកើតមានសភាពការណ៍ប្រឈមមុខដោយអាវុធ នៅបាត់ដំបង អោយមានសភាពធម្មតាវិញ ។

ប្រការ ៣ : កោះអញ្ជើញមន្ត្រីថ្នាក់ដឹកនាំរដ្ឋបាលពីខេត្តបាត់ដំបង និង មន្ត្រីដឹកនាំយោធា ពីយោធភូមិភាគទី ៥ ចំនួន ៤ រូប មកកាន់រាជធានីភ្នំពេញជាបន្ទាន់ ដូចមាន រាយនាមខាងក្រោមនេះ ÷

១–ឯកឧត្តមឧត្តមសេនីយ៍ទោ **អ៊ុង សាមី** អភិបាលខេត្តបាត់ដំបង

២–ឯកឧត្តមឧត្តមសេនីយ៍ទោ **សេរី កុសល** អភិបាលរងទី ១ ខេត្ត បាត់ដំបង

៣–ឯកឧត្តមឧត្តមសេនីយ៍ទោ **ហ៊ុល សាវ៉ន** មេបញ្ជាការយោធភូមិភាគទី ៥

៤–ឯកឧត្តមឧត្តមសេនីយ៍ទោ **ថ្លាង ចន្ទសុខវណ្ណារិទ្ធ** នាយរងសេនាធិការ យោធភូមិភាគទី ៥

ប្រការ ៤ :– រាល់ការងារដឹកនាំនៅក្នុងខេត្តបាត់ដំបង ត្រូវប្រគល់ជូនឯកឧត្តមអភិបាល រងទី ២ និង ឯកឧត្តមអភិបាលរងទី ៣ ទទួលខុសត្រូវចាត់ចែងជាបណ្តោះអាសន្ន ។

- រាល់ការងារដឹកនាំបញ្ជានៅក្នុងយោធភូមិភាគទី ៥ ត្រូវប្រគល់ជូនលោកឧត្តមសេនីយ៍ត្រី ម៉ុន សេន និង លោកឧត្តមសេនីយ៍ត្រី ខូ ឈរា មេបញ្ជាការ រងយោធភូមិភាគទី ៥ និង មេបញ្ជាការរងផ្សេងទៀតជាតំណែងជាបណ្ដោះ អាសន្ន ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារ ជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ និងឯកឧត្តមដែលមានរាយនាមក្នុងប្រការ១ ប្រការ ៣ ប្រការ ៤ និងស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III- ការងារបណ្ដាក្រសួង

១- ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ : ០២៦ សហវ.ប្រក.ពដ

ស្តីពីការតែងតាំងសមាសភាពគណៈកម្មការ

ទាយកំណៃដីមិនបានប្រើប្រាស់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១.នស.៩៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៥៨.អនក្រ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ៣១៦ ប្រក.សហវ.ពដ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសំណើរបស់ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

សំរេច

ប្រការ ១ : តែងតាំងលោក **ជា ពិសិដ្ឋ** បច្ចុប្បន្នអនុប្រធានការិយាល័យវិវាទនៃនាយកដ្ឋានពន្ធដារ ជាសមាជិកគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

ប្រការ ២ : ឯកឧត្តម អស់លោក លោកស្រី គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ហត្ថលេខា និង ត្រា

គាត់ ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រកាសលេខ : ០២៧ សហវ.ប្រក លសា
ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅ
នៃនាយកដ្ឋានលទ្ធកម្មសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស.រកម_០១៩៦_១៨ ចុះថ្ងៃទី ២៤ ខែ ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : នាយកដ្ឋានលទ្ធកម្មសាធារណៈ ជាអង្គភាពមួយស្ថិតនៅក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ២ : នាយកដ្ឋានលទ្ធកម្មសាធារណៈ ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានជាជំនួយការ ។

ប្រការ ៣ : អំពីរចនាសម្ព័ន្ធចាត់តាំង :

ក_ថ្នាក់ដឹកនាំនាយកដ្ឋាន:

ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈទទួលខុសត្រូវរួមលើរាល់កិច្ចការទាំងអស់របស់នាយកដ្ឋាន ចំពោះមុខរដ្ឋមន្ត្រី ។ រាល់សេចក្តីសំរេចដែលទាក់ទងដល់មុខងារ និងតួនាទីទទួលខុសត្រូវរបស់ នាយកដ្ឋានត្រូវបានសំរេចដោយប្រធាននាយកដ្ឋាន ។

ចំពោះសេចក្តីសំរេចដែលលើសពីសមត្ថកិច្ចរបស់ខ្លួន ប្រធាននាយកដ្ឋាន ត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យសំរេច ក្នុងករណីប្រធាននាយកដ្ឋានអវត្តមានត្រូវផ្ទេរសិទ្ធិអោយអនុប្រធាន ។ អនុប្រធានជាជំនួយការអោយប្រធាន និង ទទួលខុសត្រូវរាល់ការងារដែលប្រធានបានប្រគល់ ។

ខ_នាយកដ្ឋាន : លទ្ធកម្មសាធារណៈមានបីការិយាល័យគឺ :

- ការិយាល័យរដ្ឋបាល
- ការិយាល័យ វាយតំលៃបច្ចេកទេសទី ១
- ការិយាល័យ វាយតំលៃបច្ចេកទេសទី ២

គ_គណៈកម្មាធិការវាយតំលៃ :

គណៈកម្មាធិការវាយតំលៃមានភារកិច្ច :

- ពិនិត្យឡើងវិញ និង លើកសំណើប្រគល់កិច្ចសន្យាលើឯកសារដេញថ្លៃដែលទាក់ទិននឹងចំនួនទឹកប្រាក់មួយជាកំណត់ ផ្អែកតាមសំណើរបស់ការិយាល័យវាយតំលៃបច្ចេកទេសទី ១ និង ទី ២ ។
- ពិនិត្យអនុម័តកិច្ចការសំខាន់ ៗ របស់នាយកដ្ឋាន ។

គណៈកម្មាធិការវាយតំលៃមានសមាសភាព :

- ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ជាប្រធាន
- អនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ជាសមាជិក

- ប្រធានការិយាល័យវាយតំលៃបច្ចេកទេសទី ១ ជាសមាជិក
- ប្រធានការិយាល័យវាយតំលៃបច្ចេកទេសទី ២ ជាសមាជិក

ឃ–គណៈកម្មាធិការបែងចែកប្រភេទអ្នកទទួលការសាងសង់ :

គណៈកម្មាធិការបែងចែកប្រភេទអ្នកទទួលការសាងសង់មានភារកិច្ច :

- ពិនិត្យ និង កំណត់ការចុះឈ្មោះការបែងចែកប្រភេទ និង ចំណាត់ថ្នាក់អ្នកទទួលការសាងសង់ផ្អែកតាមសំណើរបស់ការិយាល័យវាយតំលៃបច្ចេកទេសទី ១ ។
- ពិនិត្យ និង កំណត់ការសុំតំឡើងប្រភេទ ឬ ការសុំបន្ថែមចំណាត់ថ្នាក់ផ្អែកតាមសំណើរបស់ការិយាល័យវាយតំលៃបច្ចេកទេសទី ១ ។

គណៈកម្មាធិការនេះមានសមាសភាព :

- អនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈជាប្រធាន
- តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន ជាសមាជិក
- តំណាងឧស្សាហកម្មសាងសង់ក្នុងស្រុក ជាសមាជិក

ប្រការ ៤ : តួនាទី និង ភារកិច្ច :

នាយកដ្ឋានលទ្ធកម្មសាធារណៈមានតួនាទី ត្រួតពិនិត្យនិងតាមដានអំពីការប្រតិបត្តិអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ និង ប្រកាសលេខ ១៩ សហវ.ម.ប្រក ចុះថ្ងៃទី៣១ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការអនុវត្តនីតិវិធាន និង បទបញ្ញត្តិក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ ។

នាយកដ្ឋានលទ្ធកម្មសាធារណៈមានភារកិច្ចសំខាន់ ៗ ដូចខាងក្រោម :

- ត្រួតពិនិត្យលើការងារលទ្ធកម្មសាធារណៈនៃបណ្តាក្រសួងស្ថាប័ន ខេត្ត– ក្រុង និងអង្គភាពស្វយ័តគ្រប់គ្រង ។
- ពិនិត្យ និង ចុះទិដ្ឋាការលើឯកសារដេញថ្លៃមុនពេលប្រកាសដាក់អោយដេញថ្លៃ ។
- ចូលរួមជាអ្នកអង្កេតការណ៍ពេលបើកឯកសារដេញថ្លៃ ។
- ត្រួតពិនិត្យបច្ចេកទេសឡើងវិញលើរាល់កិច្ចលទ្ធកម្មដែលទាក់ទិនដល់ ចំនួនទឹកប្រាក់ដូចមានចែងក្នុងប្រកាសៈស្តីពីការអនុវត្តនីតិវិធាន និង បទបញ្ញត្តិ ក្នុង

ការគ្រប់គ្រងលទ្ធកម្មសាធារណៈ និង តាមការកំណត់របស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

- លើកសំណើផ្តល់អនុសាសន៍ ប្រគល់កិច្ចសន្យាដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សំរេច និង ការចុះហត្ថលេខាលើកិច្ចសន្យា ។

  ចូលរួមត្រួតពិនិត្យជាមួយនាយកដ្ឋានជាគំព័ន្ធលើរាល់ការប្រគល់_ទទួល ទំនិញ សំណង់ និង សេវា ចំពោះកិច្ចសន្យាដែលមានទឹកប្រាក់ស្ថិតក្នុងការត្រួតពិនិត្យរបស់នាយកដ្ឋាន ។

- ពិនិត្យឡើងវិញ និងរៀបចំអនុសាសន៍លើករណីដោយឡែកនៃកិច្ចលទ្ធកម្ម ដែលមានមូលហេតុមកពីទំនិញចំនួនទឹកប្រាក់ ឬ លក្ខណៈពិសេស នៃគំរោងដែលចាំបាច់ត្រូវធ្វើការត្រួតពិនិត្យឡើងវិញដោយនាយកដ្ឋាន លទ្ធកម្មសាធារណៈ ។

- ត្រួតពិនិត្យការអនុវត្តនីតិវិធាន និង បទបញ្ញត្តិ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈនៅតាមក្រសួងស្ថាប័ន ខេត្ត ក្រុង និង ដាក់ចេញនូវវិធានការទាំងឡាយដើម្បីកាត់បន្ថយជាអប្បបរិមានូវ កំហុស និង ការរំលោភលើវិធាន និង បទបញ្ញត្តិនេះ ។

- ណែនាំបណ្តុះបណ្តាល និង ពង្រឹងប្រព័ន្ធលទ្ធកម្មសាធារណៈនៅតាមបណ្តាក្រសួង ស្ថាប័ន ខេត្ត ក្រុង ។

- ទទួលបន្ទុកការងារបែងចែកប្រភេទចំណាត់ថ្នាក់ និង ការចុះបញ្ជីអ្នក ទទួលការសាងសង់ ។

- ត្រួតពិនិត្យឡើងវិញនូវកិច្ចលទ្ធកម្មទាំងឡាយណា ដែលមានទំនាស់ក្នុង នោះត្រូវបង្ហាញអោយឃើញសាងសំណុំរឿង និង ផ្តល់ពត៌មានផ្សេងៗ ដែល ទាក់ទិនដល់ករណីទំនាស់ ។

- មានវិធានការចំពោះបណ្តាស្ថាប័ន ដែលបានប្រព្រឹត្តរំលោភលើវិធាន និង បទបញ្ញត្តិនៃលទ្ធកម្មសាធារណៈហើយចាំបាច់ត្រូវដាក់ចេញនូវដំណោះស្រាយណាមួយសមស្រប ។

- មានភារកិច្ចអញ្ជើញអង្គការ ឬ បុគ្គលពាក់ព័ន្ធមកឆ្លើយបំភ្លឺ នូវសំណួរផ្សេងៗ លើករណីដែលមាន លក្ខណៈពិសេសចំពោះកិច្ចលទ្ធកម្ម ។

ប្រការ ៥ : បណ្តាការិយាល័យនៃនាយកដ្ឋាន លទ្ធកម្មសាធារណៈមានភារកិច្ចជាក់ស្តែង ដូចខាងក្រោម :

ក-ការិយាល័យរដ្ឋបាល :

- រ៉ាប់រងការងារចាត់តាំង និង រដ្ឋបាលទូទៅនៅក្នុងនាយកដ្ឋាន
- គ្រប់គ្រងផ្នែកកុំព្យូទ័រ រក្សាឯកសារ និង ទិន្នន័យការងារលទ្ធកម្ម
- រៀបចំបៀវត្ស និង គ្រប់គ្រងឯកសារបុគ្គលិក
- លើកសំណើ និង ដោះស្រាយសំភារៈប្រើប្រាស់ និង សំណូមពរផ្សេង ៗ របស់ នាយកដ្ឋាន
- រៀបចំការងារបណ្តុះបណ្តាល ការងារបំពាក់បំប៉ន សិក្ខាសាលា និង ការប្រជុំផ្សេង ៗ

ខ-ការិយាល័យវាយតំលៃបច្ចេកទេសទី I :

- ធ្វើការត្រួតពិនិត្យបច្ចេកទេសឡើងវិញលើសំណើសុំប្រគល់កិច្ចសន្យាសំរាប់ការងារសាងសង់ :

ក-ភាពគ្រប់គ្រាន់ពេញលេញ និង ត្រឹមត្រូវនៃឯកសារដេញថ្លៃសំណង់ ។

ខ-ភាពត្រឹមត្រូវតាមនីតិវិធីលទ្ធកម្មរួមទាំងការផ្សព្វផ្សាយ ជូនដំណឹងអោយចូលដេញថ្លៃ ការទទួល និង បើកសំណើដេញថ្លៃ ការវាយតំលៃ ការប្រៀបធៀបសំណើដេញថ្លៃ និងការប្រគល់កិច្ចសន្យា ។

គ-ទំរង់ និង លក្ខខ័ណ្ឌនៃកិច្ចសន្យា ។

- ត្រួតពិនិត្យឡើងវិញ លើសំណើសុំប្រគល់កិច្ចសន្យាសំរាប់ការងារជ្រើស រើសសេវាទីប្រឹក្សា :

ក-ទំរង់បែបបទក្នុងការអញ្ជើញនូវសំណើរបស់ទីប្រឹក្សា ។

ខ-វាយតំលៃលើសំណើរបស់ទីប្រឹក្សា ។

គ-លក្ខខ័ណ្ឌនៃកិច្ចសន្យា ។

- ធ្វើការចុះបញ្ជីកំណត់ប្រភេទ និង ចំណាត់ថ្នាក់របស់អ្នកទទួលការសាងសង់ ។
- ចូលរួមជាអ្នកសង្កេតការណ៍ ពេលបើកឯកសារដេញថ្លៃក្នុងការងារសំណង់ និងចូលរួមក្នុងការប្រគល់ទទួលសំណង់ ។

- សិក្សាម៉ត់ចត់នូវរឿងក្តី ឬ ការប្តឹងតវ៉ាអំពីលទ្ធកម្មសំណង់ដែលអាច ជាប់ទាក់ទងជាមួយនាយកដ្ឋានលទ្ធកម្មសាធារណៈ ដើម្បីលើកយោបល់ជូនថ្នាក់ដឹកនាំពិនិត្យសំរេច ។
- ណែនាំចំពោះអង្គភាពលទ្ធកម្ម (PUS) ក្នុងការប្រតិបត្តិអោយបានត្រឹមត្រូវតាមវិធីសាស្ត្រ និង និតិវិធីលទ្ធកម្មសំណង់ ។
- ត្រួតពិនិត្យរបាយការណ៍លទ្ធកម្មសំណង់នៃបណ្តាក្រសួង–ស្ថាប័ន ខេត្ត–ក្រុង ព្រមទាំងចាត់វិធានការសមស្រប ។

គ–ការិយាល័យវាយតំលៃបច្ចេកទេសទី II :

- ធ្វើការត្រួតពិនិត្យ និង វាយតំលៃបច្ចេកទេសឡើងវិញលើសំណើសុំប្រគល់កិច្ចសន្យាសំរាប់ការផ្គត់ផ្គង់សំភារៈ និង ទំនិញ :

ក–ភាពគ្រប់គ្រាន់ពេញលេញ និង ត្រឹមត្រូវនៃបែបបទឯកសារដេញថ្លៃ ។

ខ–ភាពត្រឹមត្រូវតាមនីតិវិធីលទ្ធកម្ម រួមទាំងការផ្សព្វផ្សាយជូនដំណឹងអោយចូលរួមដេញថ្លៃ ការទទួល និង បើកសំណើដេញថ្លៃការវាយតំលៃ ការរៀបចំរៀបសំណើដេញថ្លៃ និង ការប្រគល់កិច្ចសន្យា ។

គ–ទំរង់ និង លក្ខខណ្ឌនៃកិច្ចសន្យា

- ចូលរួមជាអ្នកសង្កេតការពេលបើកឯកសារដេញថ្លៃផ្គត់ផ្គង់សំភារៈ, ទំនិញ និង ចូលរួមក្នុងការប្រគល់ - ទទួល សំភារៈ ទំនិញ ។
- សិក្សាម៉ត់ចត់នូវរឿងក្តី ឬ ការប្តឹងតវ៉ាអំពីលទ្ធកម្មទំនិញ ដែលជាប់ទាក់ទងជាមួយនាយកដ្ឋានលទ្ធកម្ម សាធារណៈដើម្បីលើកយោបល់ជូនថ្នាក់ដឹកនាំពិនិត្យសំរេច ។
- ណែនាំចំពោះអង្គភាពលទ្ធកម្ម (PUs) ក្នុងការប្រតិបត្តិអោយបានត្រឹមត្រូវតាមវិធីសាស្ត្រ និង នីតិវិធីលទ្ធកម្មទំនិញ ។
- ត្រួតពិនិត្យរបាយការណ៍លទ្ធកម្មសំភារៈ ទំនិញ នៃបណ្តាក្រសួង ស្ថាប័នខេត្ត ក្រុង ព្រមទាំងចាត់វិធានការសមស្រប ។

ប្រការ ៦ : ក្របខ័ណ្ឌមន្ត្រីរាជការ របស់នាយកដ្ឋានលទ្ធកម្មសាធារណៈ អាស្រ័យដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យសំរេច តាមសំណើរបស់ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ។

ប្រការ ៧ : ការកែប្រែប្រការណាមួយនៃប្រកាសស្តីពី ការរៀបចំ និង ការប្រព្រឹត្តិទៅនៃនាយកដ្ឋានលទ្ធកម្មសាធារណៈ ត្រូវសំរេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ៨ : ឯកឧត្តមអគ្គនាយកនាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ និង ប្រធានបណ្តាអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

អង្គការលេខ

នាយកដ្ឋាន លទ្ធកម្មសាធារណៈ

Deparment of Public Procurement (**DPP**)



២- ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ : ១៤២ ករ.ប្រក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

- អនុញ្ញាតិអោយក្រុមហ៊ុន Khaou Chuly Development Co.LTD និង ក្រុមហ៊ុន TONG YANG Cement Corporation មានអាស័យដ្ឋានផ្ទះលេខ ១៣ ផ្លូវលេខ ៣០៦ សង្កាត់បឹងកេងកង I ខ័ណ្ឌចំការមន រាជធានីភ្នំពេញធ្វើអាជីវកម្ម និងប្រើប្រាស់ថ្មកំបោរ ដើម្បីផលិតស៊ីម៉ងត៍នៅតំបន់ភ្នំទូកមាសខាងលិចដែលរួមមានកៀនខ្ចង និងភ្នំប្រកខែក (ផ្ទៃដី ៦៩៦.២៥ ហិកតា) និង ភ្នំខ្យង និងភ្នំក្បាល ទឹង (ផ្ទៃដី ៣៤៣.៧៥ហិកតា) ស្រុកបន្ទាយមាស ខេត្តកំពត លើផ្ទៃដី សរុបចំនួន ១.០៤០.០០ហិកតា ហើយដែលមានកូអរដូណេដូចតទៅ ÷

ក–ភ្នំកៀនខ្ចង និង ភ្នំប្រកខែក :

ចំណុច	អាប់ស៊ីស	អរដោណេ
A :	៤ ៤៧ ០០	១១ ៧៩ ៥០
B :	៤ ៤៨ ៥០	១១ ៧៩ ៥០
J :	៤ ៤៨ ៥០	១១ ៧៧ ២៥
I :	៤ ៤៩ ៧៥	១១ ៧៧ ២៥
H:	៤ ៤៩ ៧៥	១១ ៧៧ ០០
E:	៤ ៤៩ ៩០	១១ ៧៧ ០០
F:	៤ ៤៩ ០០	១១ ៧៦ ០០

ខ–ភ្នំខ្យង និង ភ្នំក្បាលទឹង :

G:	៤ ៤៧ ០០	១១ ៧៦ ០០
K:	៤ ៤៥ ២៥	១១ ៧៧ ៥០
L:	៤ ៤៦ ៥០	១១ ៧៧ ៥០

M:	៤ ៤៦ ៥០	១១ ៧៤ ២៥
N:	៤ ៤៥ ២៥	១១ ៧៤ ២៥

ប្រការ ២ : ក្រុមហ៊ុន Khaou Chuly Development Co.LTD និង ក្រុមហ៊ុន TONG YANG Cement Corporation ត្រូវដំណើរការធ្វើអាជីវកម្ម និង ប្រើប្រាស់ថ្មកំបោរ ដើម្បីផលិតស៊ីម៉ងត៍តាមបរិមាណដែលបានកំណត់ តំរោងវិនិយោគរបស់ខ្លួន និង ដោយធានាអនុវត្តតាមលក្ខខណ្ឌ បច្ចេកទេស អាជីវកម្ម ។

ប្រការ ៣ : ប្រកាសនេះមានតំលៃដល់ថ្ងៃទី ខែ កុម្ភៈ ឆ្នាំ ២០២៧ ។ ក្នុងកំឡុងពេល ៩០ ថ្ងៃ មុនផុតកំណត់ពេលនៃប្រកាសនេះ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណធ្វើ អាជីវកម្ម និង ប្រើប្រាស់ថ្មកំបោរដើម្បី ផលិតស៊ីម៉ងត៍បន្ត ។

ប្រការ ៤ : ប្រកាសនេះនិងត្រូវដកហូតវិញ ក្នុងករណីក្រុមហ៊ុនប្រព្រឹត្តល្មើសទៅលើលក្ខខ័ណ្ឌ នៃកិច្ចព្រមព្រៀងធ្វើអាជីវកម្ម និង ប្រើប្រាស់ថ្មកំបោរ ឬ កិច្ចព្រមព្រៀងនោះ ត្រូវបញ្ចប់តាមប្រការ ២៥ នៃ កិច្ចព្រមព្រៀង ។

ហត្ថលេខា និង ត្រា

ឡូ សុធីរៈ

* * *

ប្រកាសលេខ ១៥៣ ជក.ប្រក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក ផាន់ គីមហឿង ជនជាតិខ្មែរ សញ្ញាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៩០១៨៧ ក.ណ ចុះថ្ងៃទី ០២-១១-៩២ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៤០ ភូមិព្រែកសំរោង ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្ដាល

បន្តដំណើរការសិប្បកម្មផលិតឥដ្ឋ–ក្បឿង នៅក្នុងទីតាំង ក្រុម ៤០ ភូមិព្រែកសំរោង ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ១៥៤ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ខាំ ធូក** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២៦៥០៤ ភ.ព ចុះថ្ងៃទី ២៦–៤–៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៨ អឺ០ ផ្លូវលេខ ១៤៣ ក្រុមទី ៤០ សង្កាត់បឹងព្រលិត ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិត នំប៉័ង "យីហោ សំពៅមាស" នៅក្នុងទីតាំង ផ្ទះលេខ ៨ អឺ០ ផ្លូវលេខ ១៤៣ សង្កាត់ បឹងព្រលិត ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ១៥៥ ជក.ប្រក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **លឹម ខាន់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៦៣២៥ ភ.ព ចុះថ្ងៃទី ០៣–១២–៩៤ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១២៣ ផ្លូវលេខ ១៥៦ សង្កាត់ផ្សារដេប៉ូទី ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរការរោងជាងផ្សារ និង ជួសជុលបន្លាស់គ្រឿងយន្តនៅក្នុងទីតាំងផ្ទះលេខ ១១៣-១២៣ ផ្លូវលេខ ១៦៥ សង្កាត់ផ្សារដេប៉ូ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការ ប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៥៦ ជក.ប្រក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឌី ពិសិទ្ធ** ម្ចាស់ឧស្សាហកម្មត្បូងម្បូរពេជ្រ ដែលមានទីតាំងផ្លូវលេខ៣៣៧ សង្កាត់បឹងកក់ទី ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ផ្ទេរភារកិច្ចគ្រប់ គ្រងជូនលោក មីងៃ ឡឹតថនុភេទ្រវិញ ។

ប្រការ ២ : ទទួលស្គាល់លោក **មីងៃ ឡឹតថនុភេទ្រ** ជនជាតិថៃ សញ្ជាតិថៃ កាន់លិខិតឆ្លងដែនលេខ ១១៨៨៦០ ចុះថ្ងៃទី ១៩–០២–៩២ អាស័យដ្ឋាន បច្ចុប្បន្នផ្ទះលេខ ២៨៨–២៩២ ផ្លូវម៉ៅសេងទុង សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ជាម្ចាស់ឧស្សាហកម្មត្បូងម្បូរពេជ្រ ដែលមានទីតាំងដូចមានចែងនៅក្នុងប្រការមួយ ។

ប្រការ ៣ : លោក **មីរ៉ែ ស៊ីតេចនុតេម្ភ** ត្រូវបានអនុញ្ញាតអោយបន្តដំណើរការ ផលិតកម្ម-អាជីវកម្ម ដោយផលិតនូវមុខផលិតផលបារី SAMIT បារី KRONG THIP បារី GOLD CITY និងបារី FALLINGRAIN ស្របតាមគំរូសញ្ញាសំគាល់ដែលបានដាក់លុំកនៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

ប្រការ ៤ : ប្រកាសលេខ ៤២៦ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
អ៊ុំ ឈ្រាំង

* * *

ប្រកាសលេខ : ១៧៤ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន អ៊ិនធឺរណេសួណាល់ស្ទៀល អ៊ិនដាស់ស្ទ្រីល (INTERNATIONAL STEEL INDUTRIAL Co.LTD) តំណាងដោយលោក កាំង ម៉េងហ៊ុយ ជនជាតិខ្មែរ ភេទប្រុស អាយុ ៤៩ ឆ្នាំ អាស័យដ្ឋានផ្ទះលេខ ១២១ អឺ0 មហាវិថីសម្តេចមុនីរ៉េត សង្កាត់បឹងសាឡាង ខ័ណ្ឌទួលគោក រាជធានីភ្នំពេញកាន់អត្តសញ្ញាណប័ណ្ណលេខ ២៨៣៨១៩ ភព ចុះថ្ងៃទី ១៣.៨.៩០ "

បង្កើតរោងចក្រកែច្នៃសង្កសី " ដែលមានឈ្មោះថា " រោងចក្រកែច្នៃសង្កសី អ៊ុន ធីរណោស្ទណល់ " មានទីតាំងស្ថិតនៅក្រុមទី ៥០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ការសាងសង់និងរៀបចំគ្រឿងចក្រ ត្រូវធ្វើទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អោយបានសំរេចក្នុងរយៈពេល ៩ ខែ ដោយរាប់បញ្ចូលទាំងរយៈពេលសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះ ត្រូវបានអនុញ្ញាតអោយផលិត " សង្កសីសន្លឹក " ទៅតាមគំរូ និងផ្លាកសញ្ញាដែលតំកល់ ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ពូ សុធីរៈ

* * *

ប្រកាសលេខ : ១៨៩ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ងាម ចិន្ត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០០៦៨៣ប.ប ចុះថ្ងៃទី ២៨–៨–៨៥ អាស័យដ្ឋានបច្ចុប្បន្ន ភូមិអូរចារ ឃុំអូរចារ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការរោងជាងទ្វារបង្អួច របងដែក នៅក្នុងទីតាំងភូមិអូរចារ ឃុំអូរចារ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ១៦០ ឧក. ប្រក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

